នាងអេសធើរ៣:៧-៤:២

**រីឯនៅឆ្នាំ១២ក្នុងរាជ្យអ័ហាស៊្វេរុស គឺនៅខែទី១ ជាខែចេត្រ នោះ គេវាយលេខតាមរបៀន "ពោរ" នៅមុខហាម៉ាន ដេញរកថ្ងៃខែ ទៅទល់នឹងខែ១២ ទើបត្រូវ គឺជាខែផល្គុន (នាងអេសធើរ៣:៧)។**

រៀងរាល់ថ្ងៃ លោកហាម៉ានមានឆ្អឹងមួយកំពុងជាប់ទទឹងកលោក។ ពេលលោកចេញចូលតាមទ្វារក្រុង នរណាក៏ដោយ ទោះមានបុណ្យស័ក្តិប៉ុណ្ណាសុទ្ធតែឱនក្រាបនៅចំពោះលោកទាំងអស់ លើកលែងតែលោកម៉ាដេកាយជាសាសន៍យូដាម្នាក់ប៉ុណ្ណោះ។ កិរិយាដែលលោកម៉ាដេកាយធ្វើចំពោះលោកហាម៉ាន ប្រៀបឧបមាដូចជាបន្លាតូចមួយកំពុងទល់ត្របកភ្នែកលោកហាម៉ាន។ ដូច្នេះ លោកហាម៉ានគិតធ្វើការមួយដែលធ្វើអោយលោកម៉ាដេកាយ និងជាតិសាសន៍របស់លោកត្រូវវិនាសទាំងអស់តែម្តង។ លោកដឹងថា មូលហេតុដែលលោកម៉ាដេកាយមិនគោរពដល់លោក គឺមកពីសាសនារបស់បុគ្គលនេះ។ លោកហាម៉ាននឹងធ្វើគម្រោងការសម្លាប់ជាតិសាសន៍យូដាអោយអស់ចេញពីនគរទាំងមូល។ លោកយល់ថា បើសម្លាប់សាសន៍យូដាទូទៅក្នុងចក្រភពពើស៊ីទាំងមូល លោកលែងមាននរណាឈររាំងផ្លូវលោកទៀតហើយ។

លោកហាម៉ានជានាយករដ្ឋមន្ត្រី ជឿលើក្បួនទស្សន៍ទាយគឺក្បួន "ពោរ"។ លោកបានហៅគ្រូទស្សន៍ទាយមករាប់ជើងរាប់ដៃ ដេញរកពេលាដើម្បីអោយដឹងថា

ថ្ងៃណាជារាសីល្អសម្រាប់បំផ្លាញសាសន៍យូដាអោយខ្ទេចខ្ទី។ គ្រូហោរទាយនិងហាម៉ាន មិនដឹងថា ព្រះជាម្ចាស់អាចទម្លាក់ពលាអោយត្រូវនឹងផែនការគេទេ។ ព្រះជាម្ចាស់អាចបំផ្លាស់បំប្រែស្ថានភាពដ៏អាក្រក់នោះបាន។ ថ្ងៃខែដែលគ្រូហោរទាយរកឃើញថា ជារាសីល្អដើម្បីបំផ្លាញសាសន៍យូដា គឺជាថ្ងៃដែលព្រះជាម្ចាស់កំណត់ទុកថា ជាថ្ងៃអវសាននៃជីវិតរបស់លោកហាម៉ាន។

> **៨ នោះហាម៉ានទូលដល់ស្តេចអ័ហាស៊ូរុសថា មានសាសន៍១ ដែលខ្ចាត់ខ្ចាយនៅកណ្តាលសាសន៍ទាំងប៉ុន្មាន ក្នុងគ្រប់ទាំងអាណាខេត្តរបស់ទ្រង់ គេមានច្បាប់ខុសពីច្បាប់នៃសាសន៍ទាំងអស់ ក៏មិនកាន់តាមច្បាប់របស់ព្រះករុណាផង ដូច្នេះ មិនគួរឱ្យព្រះករុណាទុកឱ្យគេនៅទៀតទេ ៩ បើសិនជាព្រះករុណាទ្រង់សព្វព្រះទ័យ នោះសូមទ្រង់បង្គាប់ឱ្យមានច្បាប់កត់ទុក ឱ្យបំផ្លាញពួកនោះចេញ យ៉ាងនោះទូលបង្គំនឹងប្រគល់ប្រាក់១ម៉ឺនហាបទៅក្នុងឃ្លាំងហ្លួងទាំងប៉ុន្មាន សំរាប់ពួកអ្នកដែលចាត់ចែងការនោះ (នាងអេសធើរ៣:៨–៩)។**

លោកហាម៉ានចូលទៅទូលស្តេចស៊ូរុសថា នៅក្នុងនគររបស់ព្រះរាជាមានមនុស្សមួយពួកដែលរស់នៅមិនចុះចំណោមនឹងគេ។ អ្នកទាំងនោះស្តាប់តាមក្រឹត្យវិន័យ

របស់លោកម៉ូសេ។ ដោយសារជាតិសាសន៍ទាំងនោះ រស់នៅក្នុងនគរមិនចុះចំណោម បើទុកក៏មិនចំណេញ ដកចេញក៏មិនខាត ដូច្នេះសម្លាប់គេចោលទាំងអស់តែម្តងទៅ។ លោកហាម៉ានពន្យល់ដល់ស្តេចថា បើព្រមសម្លាប់សាសន៍យូដាទាំងអស់ បញ្ហាជាតិក៏ត្រូវដោះស្រាយបានមួយកម្រិតយ៉ាងធំដែរ។ ទ្រព្យសម្បត្តិរបស់សាសន៍យូដាអាចប្រមូលដាក់ឃ្លាំងបានរាប់ពាន់ហាប សម្រាប់បង្គ្រប់ថវិកាជាតិដែលកំពុងតែខ្វះខាត។ ស្តេចស៊ូរុសទើបនឹងចំណាយថវិកាជាតិរាប់កោដិដុល្លា ដើម្បីធ្វើសង្គ្រាមទាស់នឹងសាសន៍ក្រេក។ ដោយសារសង្គ្រាមនោះ ស្តេចស៊ូរុសត្រូវការប្រាក់កាសយកមកបំពេញថវិកាជាតិដែលកំពុងតែទ្រុឌទ្រោម។ ស្តេចស៊ូរុសឃើញច្រកមួយនេះថា ជាដំណោះស្រាយដើម្បីដោះស្រាយបញ្ហាថវិកាជាតិនៅក្នុងនគររបស់ទ្រង់។ ធម្មតាអ្នកនយោបាយគេគិតតែត្រឹមប៉ុណ្ណោះ គឺគេគិតតែរឿងលុយ ដើម្បីអោយអាចបំពេញការងារដែលគេត្រូវធ្វើនៅក្នុងនគរ។

ម្យ៉ាងទៀតសូមលោកអ្នកកត់ចំណាំថា ស្តេចស៊ូរុសមិនគោរពដល់ជីវិតមនុស្សឡើយ។ មាន់មួយក្បាលប្រហែលជាថ្លៃជាងជីវិតមនុស្សសម័យនោះ។ នៅពេលដែលហាម៉ានយករឿងជាតិសាសន៍មួយពួកយកមកទូលថ្វាយដល់ស្តេច ស្តេចមិនខ្វីទាំងសួរថា តើហាម៉ានចង់សម្លាប់ផ្តាច់ពូជជាតិសាសន៍ណាមួយផង។ លោកហាម៉ានមិនដឹងថានាងអេសធើរ ដែលត្រូវជាអគ្គមហេសីរបស់ស្តេចជាសាសន៍យូដាទេ។ ម្យ៉ាងទៀតស្តេចស៊ូរុសក៏មិនបានជ្រាបថា ព្រះនាងអេសធើរជាសាសន៍យូដាដែរ។ តាមពិត នៅពេលស្តេចអង្គនេះ ចុះហត្ថលេខាព្រមព្រៀងអោយហាម៉ានសម្លាប់សាសន៍យូដា ស្តេច

ស៊ូរុសបានអោយហាម៉ានសម្លាប់អគ្គមហេសីរបស់ទ្រង់ដែរ។

**ដូច្នោះ ស្ដេចទ្រង់ដោះព្រះទំរង់ពីព្រះហស្ដប្រគល់ដល់ហាម៉ាន ជាកូនហាំម្ដាថា សាសន៍អ័កាក់ ជាខ្មាំងសត្រូវពួកយូដា (នាងអេសធើរ៣:១០)។**

ស្ដេចស៊ូរុស ដោះចិញ្ចៀនត្រារបស់ទ្រង់ប្រគល់ដល់លោកហាម៉ានជានាយករដ្ឋមន្ត្រី។ ព្រះរាជាសម័យនោះពាក់ចិញ្ចៀន ឯចិញ្ចៀននោះទៀតសោត គឺជាត្រាសម្រាប់ប្រថាប់ដល់សេចក្ដីផ្សេងៗ ដែលបានចែងដើម្បីធ្វើជាច្បាប់របស់ព្រះរាជាណាចក្រពើសីទាំងមូល។ ដូច្នេះ ក្នុងកាលៈទេសៈបែបនេះ ស្ដេចស៊ូរុសបានប្រគល់ចិញ្ចៀនត្រារបស់ទ្រង់ដល់ហាម៉ាន ដោយមិនបានពិចារណាអ្វីបន្តិចបន្តួចសោះ។ នៅពេលប្រគល់ចិញ្ចៀនត្រាដល់ហាម៉ាន ស្ដេចស៊ូរុសមានបន្ទូលទៅកាន់ហាម៉ានថា "យើងមិនខ្វល់ពីរបៀបណា វិធីណា ឬជនណា ដែលលោកយកចិញ្ចៀនត្រានេះទៅប្រើទេ បើលោកយល់ថាមនុស្សទាំងនោះ ជាឆ្អឹងទទឹងកសម្រាប់យើង សូមសម្លាប់ផ្ដាច់ពូជទៅចុះ"។ ស្ដេចស៊ូរុស មិនគោរពតម្លៃជីវិតមនុស្សទាល់តែសោះ។ បើតាមប្រវត្តិសាស្ត្ររបស់សកលលោក ពេលធ្វើសង្គ្រាមជាមួយនឹងសាសន៍ក្រេក ស្ដេចអង្គនេះបញ្ជូនពលទ័ពជាច្រើនលាននាក់អោយស្លាប់ដោយគ្មានយុទ្ធសាស្ត្រត្រឹមត្រូវ។ គេប៉ាន់ថា កងទ័ពដែលស្លាប់នោះ មានប្រមាណជាជាងពីរលាននាក់។ ការសម្លាប់មនុស្សពីរលាន

នាក់ មិនធ្វើអោយស្តេចអង្គនេះមានព្រះហឫទ័យព្រួយអ្វីបន្តិចទេ។ ស្តេចអង្គនេះបានសម្រេចចិត្តយ៉ាងឆោតល្ងង់។ ប៉ុន្តែ ទោះបីជាការឆោតល្ងង់ក៏ដោយ មនុស្សពីរលាននាក់ស្លាប់ ហាក់ដូចជាស្លាប់ស្រមោចមួយសំបុកតែប៉ុណ្ណោះ។ ស្តេចអង្គនេះមិនអោយតម្លៃដល់ជីវិតមនុស្សសូម្បីបន្តិចបន្តួចសោះក៏គ្មានដែរ។

**[១១]ដោយបន្ទូលថា ប្រាក់នោះយើងបានអនុញ្ញាតឱ្យអ្នកហើយ**
**ព្រមទាំងសាសន៍នោះផង ដើម្បីឱ្យអ្នកធ្វើដល់គេ តាមតែគិត**
**ឃើញថាល្អចុះ [១២]នៅថ្ងៃ១៣ខែចេត្រ គេបានហៅពួកស្មៀនហ្លួង**
**មក កត់គ្រប់ទាំងសេចក្តីដែលហាម៉ានបង្គាប់ដល់ពួកចៅហ្វាយ**
**ខេត្តរបស់ស្តេច ពួកចៅហ្វាយដែលត្រួតនៅគ្រប់តែស្រុក នឹងពួក**
**មេនៃគ្រប់ទាំងសាសន៍ គឺដល់គ្រប់ខេត្តតាមអក្សរជាតិរបស់គេ**
**ហើយដល់គ្រប់សាសន៍ តាមភាសារបស់គេ ច្បាប់នោះបានកត់**
**ទុកដោយនូវព្រះនាមស្តេចអ័ហាស៊ូរុស ក៏បោះត្រាដោយព្រះទំរង់**
**របស់ស្តេចដែរ [១៣]ហើយគេផ្ញើសំបុត្រទាំងនោះ ទៅគ្រប់ទាំងខេត្ត**
**របស់ស្តេច ដោយសារពួកអ្នករត់សំបុត្រ បង្គាប់ឱ្យបំផ្លាញសំឡាប់**
**ហើយធ្វើឱ្យពួកសាសន៍យូដាទាំងអស់វិនាសបង់ ទោះទាំងចាស់**
**ទាំងក្មេង នឹងកូនង៉ែត ហើយស្ត្រីៗផង ក្នុងរវាង១ថ្ងៃកំណត់នោះ**
**ដែលត្រូវជាថ្ងៃ១៣ខែ១២ គឺជាខែផល្គុន ព្រមទាំងរឹបជាន់យក**

## ទ្រព្យសម្បត្តិគេផង (នាងអេសធើរ៣:១១-១៣)។

ព្រះរាជក្រឹត្យដែលបញ្ជាអោយសម្លាប់សាសន៍យូដា ក្លាយទៅជាច្បាប់របស់សាសន៍មីឌនិងសាសន៍ពើស៊ី។ ដើម្បីបញ្ជូនព្រះរាជក្រឹត្យអោយទៅដល់ទីកន្លែងនិងពេលដែលត្រូវទៅដល់ ត្រូវមានការខិតខំប្រឹងប្រែងយ៉ាងខ្លាំង។ នគរពើស៊ីមាននគរចំណុះចំនួន១២៧។ ចក្រភពនេះលាតសន្ធឹងចាប់ពីពាក់កណ្ដាលទ្វីបអាស៊ីចុះទៅដល់ទ្វីបអឺរុប ហើយឡើងមកដល់ទ្វីបអាហ្វ្រិកថែមទៀតផង។ យ៉ាងហោចណាស់នៅក្នុងនគរទាំង ១២៧ មាន១២៧ភាសាដែរ។ នៅមិនទាន់គិតក្នុងនគរនីមួយៗ មាននិយាយភាសាជាច្រើនបែបច្រើនយ៉ាងទៀត។ ដូច្នេះ ព្រះរាជក្រឹត្យនោះ ត្រូវបកប្រែអោយគ្រប់ភាសាមនុស្ស ដែលរស់នៅក្នុងចក្រភពពើស៊ីទាំងមូល។ អ្នកបកប្រែធ្វើការយ៉ាងសកម្ម។ គម្រោងរបស់រដ្ឋាភិបាលមួយនេះ ជាគម្រោងការយ៉ាងធំហើយចំណាយលុយជាច្រើនកោដិដុល្លាថែមទៀត។ ឯការបោះពុម្ពព្រះរាជក្រឹត្យក៏ត្រូវធ្វើអោយបានច្រើនតាមគ្រប់ភាសាដែរ។ លុះព្រះរាជក្រឹត្យបានបោះពុម្ពគ្រប់ភាសារួចហើយ គេក៏បញ្ជូនអ្នករត់សំបុត្រ ខ្លះជិះអូដ្ឋ ខ្លះជិះសេះ ដើម្បីចេញដំណើរទៅតាមកន្លែងដែលគេត្រូវទៅ។ នៅថ្ងៃកំណត់ គេត្រូវសម្លាប់សាសន៍យូដាអោយដាច់ពូជទាំងអស់តែម្ដង។ ច្បាប់នេះ គឺជាច្បាប់ប្រឆាំងជាមួយពួកកូនចៅលោកសិម។ នៅថ្ងៃដែលព្រះរាជក្រឹត្យបានកំណត់ ជនណាក៏ដោយ ក៏មានសិទ្ធិសម្លាប់សាសន៍យូដាត្រូវតាមច្បាប់ដែរ។ ការសម្លាប់ជាផ្លូវការណ៍ ត្រូវកើតមានឡើងនៅថ្ងៃដែលលោកហាម៉ាន ហើយនិងស្ដេចស៊្ស៊ែរុសបានកំណត់

ទុក។

ដូចខ្ញុំបានជម្រាបរួចហើយថា ព្រះរាជក្រឹត្យនេះ គឺជាច្បាប់សម្រាប់សាសន៍មីឌ និងសាសន៍ពើស៊ី។ ម្យ៉ាងវិញទៀតច្បាប់ដែលបានចេញហើយ នៅក្នុងប្រពៃណីទំនៀមទម្លាប់របស់ជនជាតិមីឌ និងជនជាតិពើស៊ី មិនអាចកែប្រែបានជាដាច់ខាត។ បើចង់កែប្រែច្បាប់នេះ គេត្រូវមានច្បាប់មួយទៀតដែលត្រូវចេញមកបង្ក្រាប ហើយអ្នកដែលចេញច្បាប់នោះត្រូវមានអំណាចលើសជាងស្ដេច និងជាងហាម៉ាន។

យើងដឹងថា ស្ដេចស៊ូរុសគ្រងរាជ្យលើនគរ១២៧ តើមានស្ដេចណាមួយទៀតដែលធំជាងនេះអាចកែប្រែព្រះរាជក្រឹតរបស់ទ្រង់បាន? យើងនឹងសិក្សារឿងនេះជាបន្តទៅទៀត។

**[១៤] ឯសំបុត្រទាំងនោះមានចំឡងព្រះរាជឱង្ការ ដែលត្រូវប្រកាស**
**ប្រាប់ដល់គ្រប់ទាំងសាសន៍ នៅអស់ទាំងខេត្តផង ឱ្យគេបានប្រុង**
**ប្រៀបជាស្រេចនៅថ្ងៃនោះ**
**[១៥] ពួករត់សំបុត្រក៏ចេញទៅជាប្រញាប់ តាមបង្គាប់របស់ស្ដេច ហើយព្រះរាជឱង្ការនោះបានប្រកាសប្រាប់ នៅក្នុងស៊ូសាន ជាក្រុងហ្លួងដែរ រួចស្ដេច នឹងហាម៉ានក៏នាំគ្នាបរិភោគស្រា តែទីក្រុងស៊ូសានមានសេចក្ដីស្រឡាំងកាំងនៅ (នាងអេសធើរ៣:១៤-១៥)។**

ទីក្រុងស៊ូសានមានភាពស្ងាត់ជ្រងំ ពីព្រោះគេទទួលការរងទុក្ខ។ អ្នកផងទាំងពួង ដែលជាពលរដ្ឋរស់នៅក្នុងទីក្រុងស៊ូសាន យល់ថាសាសន៍យូដា មិនបានធ្វើអ្វីដែលអោយសមនឹងពាក្យដែលគេចោទប្រកាន់ថាក្បត់ជាតិទេ។ គេជាសាសន៍ដែលមិនបានប្រព្រឹត្តអំពើអាក្រក់ណាមួយ សមនឹងទទួលទោសបែបនេះសោះ។ ប្រជាពលរដ្ឋដែលរស់នៅក្នុងទីក្រុងស៊ូសានយល់ថា ហេតុអ្វីបានជាស្តេចចេញបញ្ជាដោយអយុត្តិធម៌យ៉ាងដូច្នេះ? គេយល់ថា មែនហើយសាសន៍យូដា គេប្រកាន់សាសនារបស់គេណាស់ ប៉ុន្តែទោះបីយ៉ាងនោះក៏ដោយ ស្តេចមិនត្រូវសម្លាប់គេផ្តាច់ពូជដោយគ្រាន់តែគោរពសាសនាខុសពីអ្នកឯទៀត។ គេមិនយល់ថា ហេតុអ្វីបានជាព្រះរាជាចេញបញ្ជាយ៉ាងទទឹងទទែងដូច្នេះសោះ។ នៅក្នុងផ្ទៃព្រះរាជវាំងទាំងមូល មានការរវល់ខ្លាំងណាស់ ដ្បិតគេឃើញមានសេះ មានលា មានអូដ្ឋគ្រប់បែបយ៉ាងធ្វើដំណើរចេញទៅយ៉ាងគគ្រឹកគគ្រេង។ រាជរដ្ឋាភិបាលបានជួលក្រុមហ៊ុនបញ្ជូនសំបុត្រជាច្រើន ពោលគឺក្រុមហ៊ុនខ្លះបញ្ជូនព្រះរាជក្រឹត្យទៅទិសខាងកើត ខ្លះទៅទិសខាងត្បូង ខាងជើង ខាងលិច គឺទិសទាំងប្រាំបី។ អ្នកបញ្ជូនសំបុត្រត្រូវធ្វើដំណើរទាំងយប់ទាំងថ្ងៃ។ នៅពេលគេធ្វើដំណើរទៅដល់ទីក្រុងមួយ គេយកព្រះរាជក្រឹត្យទៅបិទប្រកាសផ្សាយ រួចហើយគេធ្វើដំណើរឆ្ពោះទៅទីក្រុងមួយទៀត។ នៅពេលសេះមួយអស់កម្លាំង អ្នកកាន់រាជ្យទ្រព្យដែលនៅក្នុងទីក្រុងនោះត្រូវបញ្ចេញសេះថ្មីមួយទៀតដល់អ្នកជិះ ដើម្បីអោយគេធ្វើដំណើរបានយ៉ាងលឿនជាទីបំផុត។ នៅក្នុងចក្រភពពើស៊ីទាំងមូល ដែលមាននគរ១២៧ជាចំណុះដឹងថា នៅថ្ងៃមួយគេត្រូវសម្លាប់សាសន៍យូដា ដោយគ្មានទោសពៃរ៍អ្វីទេ។ អ្នករត់សំបុត្រចេញទៅ

យ៉ាងប្រញាប់ ដ្បិតគេធ្វើតាមបញ្ជារបស់ព្រះរាជា។ មែនហើយ អ្នកស្តាប់តាមបង្គាប់ស្តេច ធ្វើការដោយចិត្តក្លាហាននឹងរីករាយ តែអ្នកស្រុកនៅទីក្រុងស៊ូសានវិញនាំគ្នាព្រួយបារម្ភ។ ប៉ុន្តែ ទោះបីប្រជាពលរដ្ឋនៅក្នុងទីក្រុងទាំងមូល មានការព្រួយបារម្ភក៏ដោយ ស្តេចគ្មានចិត្តអាណិតអាសូរអ្វីបន្តិចបន្តួចទេ។ ស្តេចអង្គនេះ និងលោកហាម៉ានកញ្ចាស់ នាំគ្នាផឹកស្រាស្រវឹងទោររៀងរាល់ពេលល្ងាច។ ព្រះរាជាវ័យចំណាស់មួយនេះគិតថាយប់នេះនឹងចូលទៅឯនាងអេសធើរ បន្ទាប់ពីស្រវឹងស្រាហើយ។ ប៉ុន្តែ ស្តេចអង្គនេះពុំបានដឹងថា ច្បាប់ដែលស្តេចនេះចេញជាព្រះរាជក្រឹត្យ កំពុងតែប៉ះពាល់ដល់ជីវិតនាងអេសធើរ ដែលត្រូវជាអគ្គមហេសីរបស់ខ្លួនទេ។

នៅក្នុងលោកនេះ មានមនុស្សជាច្រើនណាស់ស្អប់សាសន៍អ៊ីស្រាអែល។ គ្រីស្ទបរិស័ទមិនគួរមានចំណែកក្នុងការស្អប់សាសន៍អ៊ីស្រាអែល ទោះបីក្នុងរូបភាពណាក្តី។ ហេតុអ្វីបានជាមានគេស្អប់ដល់សាសន៍អ៊ីស្រាអែលខ្លាំងម្ល៉េះ? សំអប់ដល់សាសន៍អ៊ីស្រាអែល ចាប់ផ្តើមពីដំណាក់ផារ៉ោនពេលដែលគេប្រើសាសន៍នេះ អោយសង់ទីក្រុងនៅប្រទេសអេស៊ីព្ទ។ គេចង់សម្លាប់សាសន៍យូដា មិនអោយមានសល់ពូជពង្សតទៅទៀត។ ចាប់ពីពេលនោះមក មនុស្សនៅលើលោកនេះស្អប់សាសន៍អ៊ីស្រាអែលខ្លាំងណាស់។ ចក្រភពអាស៊ើរ ចក្រភពបាប៊ីឡូនបានប៉ុនប៉ងសម្លាប់សាសន៍នេះមិនអោយសល់ម្នាក់។ ឥឡូវនេះ នៅក្នុងគម្ពីរនាងអេសធើរ យើងឃើញថាចក្រភពពើស៊ីកំពុងតែព្យាយាមសម្លាប់សាសន៍យូដាអោយដាច់ពូជដែរ។ រាជការរ៉ូមក៏ត្រូវទោសដោយសាររឿងនេះ។ ម្យ៉ាងទៀតពួកអេស្ប៉ាញ បានធ្វើការលុកលុយប្រទេសនានា គេក៏សម្លាប់

សាសន៍យូដាអស់ជាច្រើនលាននាក់។ នៅក្នុងប្រវត្តិសាស្ត្រថ្មីៗនេះ លោកអ៊ីត្លែ ជាសាសន៍អាល្លឺម៉ង់ បានព្យាយាមសម្លាប់សាសន៍យូដាអស់ប្រាំមួយលាននាក់ ដោយមានបំណងចិត្តចង់រំលាយជាតិសាសន៍នេះអោយបាត់អស់ពីផែនដី។ តើមូលហេតុអ្វីបានជានគរនានាស្អប់សាសន៍យូដា ស្អប់សាសន៍អ៊ីស្រាអែលម្ល៉េះ? ខ្ញុំយល់ថាមានមូលហេតុពីរយ៉ាង។ មូលហេតុទីមួយ គឺជាបញ្ហាសាច់ឈាម ឯមូលហេតុទីពីរ គឺជាបញ្ហាខាងព្រលឹងវិញ្ញាណ។

ខាងសាច់ឈាម គេមើលឃើញថា សាសន៍យូដាជាសាន៍ដែលមិនគួរនឹងរស់នៅ អោយបានថ្លៃថ្នូរដូចយើងឃើញសព្វថ្ងៃនេះទេ។ ខ្ញុំចង់អោយលោកអ្នកបងប្អូនកុំអោយយល់ច្រឡំខ្ញុំអោយសោះ។ ខ្ញុំស្គាល់សាសន៍យូដាមួយរូបដែលជឿដល់ព្រះអម្ចាស់។ លោកម្នាក់នោះបានជួយទំនុកបម្រុងក្រុមជំនុំខ្មែរយើងខ្លាំងណាស់ នៅពេលដែលក្រុមជំនុំខ្មែរដែលខ្ញុំធ្វើជាគ្រូគង្វាលបានចាប់ផ្ដើមឡើង។ លោកមានសន្ដានចិត្តល្អចំពោះខ្ញុំនិងចំពោះខ្មែរយើងយ៉ាងខ្លាំង ពីព្រោះលោកយល់ថា ខ្មែរយើងបានឆ្លងកាត់គ្រោះកាចដូចសាសន៍យូដាដែរ។ ប៉ុន្តែ ទោះបីជាលោកម្នាក់នោះមានសន្ដានចិត្តល្អក៏ដោយ យើងត្រូវប្រឈមមុខនឹងសេចក្ដីពិត។ មនុស្សដែលគ្មានព្រះ ទោះជាសាសន៍យូដា ទោះជាសាសន៍ដទៃ សុទ្ធតែជាមនុស្សមិនគួររស់នៅលើលោកនេះទេ។ ពិភពលោកនេះ ជារបស់ព្រះជាម្ចាស់។ អ្នកដែលមិនទទួលស្គាល់ព្រះជាម្ចាស់ រស់នៅលើផែនដីដែលជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់ តើនរណាមួយដែលសមនឹងរស់នៅលើទឹកដីរបស់អ្នកដទៃ? ព្រះជាម្ចាស់សម្លឹងមើលពីបង្អួចដំណាក់ទ្រង់ ឃើញមនុស្សគ្រប់រូបសុទ្ធតែជាមនុស្ស

ដែលមិនគួរ។ គេមានកិរិយាឆ្អិនក្រៅឆៅក្នុង។ ប៉ុន្តែ ព្រះគុណរបស់ព្រះបានគ្របដណ្តប់មកលើយើងគ្រប់គ្នាជាមនុស្សមានបាប។ ព្រះជាម្ចាស់មិនគួរផ្តល់ព្រះគុណដល់មនុស្សយើងទេ។ ផ្ទុយទៅវិញ ទ្រង់បានធ្វើអោយយើងក្លាយទៅជាមនុស្សដែលមានកំណើតថ្មីនៅក្នុងព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ព្រះគុណរបស់ព្រះល្អ ប្រសើរ បរិបូរ ហើយគ្របដណ្តប់លើយើងគ្រប់គ្នា។ គេស្អប់សាសន៍យូដា ពីព្រោះព្រះជាម្ចាស់បានផ្តល់ព្រះគុណដល់សាសន៍នេះ គឺផ្តល់សេចក្តីសង្គ្រោះដល់សាសន៍នេះ ក៏ដូចជាផ្តល់ដល់យើងរាល់គ្នាដែលជាមនុស្សមានបាបដែរ។

ឯខាងព្រលឹងវិញ្ញាណ គេមានគំនិតទាស់ទទឹងនឹងសាសន៍អ៊ីស្រាអែល មកពីគេច្រណែននឹងសាសន៍នេះតែម្តង។ ព្រះជាម្ចាស់បានផ្តល់ព្រះគុណរបស់ទ្រង់ជាបរិបូរ ដើម្បីអោយព្រះបន្ទូលរបស់ព្រះអង្គសអាចសម្តែងមក ជាភាសាមនុស្សជាតិ។ ទ្រង់បានត្រាស់ហៅសាសន៍យូដា អោយធ្វើជាស្មៀនរបស់ទ្រង់ ក្នុងការសរសេរព្រះបន្ទូលរបស់ទ្រង់អោយមនុស្សលោកបានដឹង។ គម្ពីរដែលយើងកាន់សព្វថ្ងៃនេះ បានមកពីព្រះតាមរយៈសាសន៍យូដា។ ព្រះជាម្ចាស់ជ្រើសរើសសាសន៍យូដា ដើម្បីសរសេរព្រះគម្ពីររបស់ទ្រង់។ សាសន៍យូដាសរសេរព្រះគម្ពីរតាមភាសារបស់គេ ដែលព្រះជាម្ចាស់បានបង្គាប់មក។ ដោយសារមូលហេតុនេះហើយ សាតាំងស្អប់សាសន៍យូដាណាស់ ពីព្រោះសាសន៍នេះឯង ដែលបើកសម្តែងអោយស្គាល់គំនិតរបស់ព្រះជាម្ចាស់ ទាក់ទងនឹងឧបាយកលអាក្រក់របស់សាតាំង។ ម្យ៉ាងវិញទៀត សាតាំងស្អប់សាសន៍អ៊ីស្រាអែល ពីព្រោះដោយតាមបទគម្ពីរ ព្រះអម្ចាស់យេស៊ូវត្រូវប្រសូតមកលើលោកនេះ ជាសាសន៍អ៊ីស្រាអែល។

សាវ័កប៉ុលមានប្រសាសន៍ថា "ហើយព្រះគ្រីស្ទក៏បានកើតពីពួកគេ ខាងឯសាច់ឈាមដែរ ដែលទ្រង់ខ្ពស់លើសទាំងអស់ ជាព្រះដ៏មានពរអស់កល្បជានិច្ច អាម៉ែន" (រ៉ូម៩:៥)។ ដោយសារព្រះជាម្ចាស់ជ្រើសរើសប្រើសាសន៍អ៊ីស្រាអែល សម្រាប់ជាប្រយោជន៍ដល់មនុស្សជាតិទាំងមូល ដែលរស់នៅលើលោកយើងនេះ ការច្រណែនចំពោះសាសន៍យូដា ក៏កើតមានឡើង។ គេស្អប់សាសន៍យូដា ពីព្រោះសាតាំងស្អប់សាសន៍នេះជាមុន។ ព្រះអង្គអោយយើងដឹងថា ព្រះជាម្ចាស់បានជ្រើសរើសសាសន៍អ៊ីស្រាអែលធ្វើជារាស្ត្ររបស់ទ្រង់។ ក្នុងនាមសាសន៍អ៊ីស្រាអែលជារាស្ត្ររបស់ទ្រង់ គេក៏ជាជាតិសាសន៍មួយនៅលើនគរនេះដែរ។ សាតាំងស្អប់សាសន៍យូដា ហើយជាលទ្ធផល សាសន៍ឯទៀតដែលស្តាប់តាមសាតាំង ក៏ស្អប់សាសន៍យូដាដូចសាតាំងដែរ។

ច្បាប់របស់ស្តេចស៊ូរុសមិនអាចកែប្រែបាន។ ការនេះយើងឃើញរួចមកហើយ ក្នុងករណីព្រះនាងវ៉ាសធីមិនស្តាប់បង្គាប់ដល់បញ្ជារបស់ស្តេច។ ព្រះរាជក្រឹត្យដែលបញ្ជាអោយសម្លាប់សាសន៍យូដាទាំងនគរ ក៏មិនអាចកែប្រែបានដែរ ពីព្រោះជាច្បាប់របស់សាសន៍មីឌ និងសាសន៍ពើស៊ី។ គ្មានមធ្យោបាយអ្វីដែលអាចប្តូរផ្លាស់ច្បាប់នោះបានឡើយ។ បើយ៉ាងដូច្នេះមែន តើព្រះជាម្ចាស់អាចសង្គ្រោះរាស្ត្រទ្រង់ដោយវិធីណា? ដើម្បីសង្គ្រោះរាស្ត្រទ្រង់ ត្រូវមានច្បាប់មួយទៀត។ ឯច្បាប់នោះទៀតសោតត្រូវចេញបញ្ជាដោយអ្នកដែលមានអំណាចខ្ពស់ ជាងស្តេចដែលគ្រប់គ្រង១២៧នគរ។ តើស្តេចអង្គនោះ គឺជាអង្គណា? ព្រះជាម្ចាស់កំពុងរៀបចំផ្លូវដើម្បីធ្វើការនេះហើយ គឺព្រះអង្គធ្វើដើម្បីប្តូរផ្លាស់ច្បាប់នោះទាំងស្រុង។

នៅពេលដែលយើងចាប់ផ្តើមសិក្សាព្រះគម្ពីរនាងអេសធើរ យើងបាននិយាយសង្កត់ធ្ងន់លើការឧបត្ថម្ភគាំទ្ររបស់ព្រះជាម្ចាស់។ ព្រះអង្គបើកសម្តែង អោយយើងឃើញស្ថានភាពដែលកើតឡើងជាក់ស្តែង នៅក្នុងផ្ទៃវាំងរបស់ស្តេចដែលមិនស្គាល់ដល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ស្តេចដែលគ្រប់គ្រង១២៧នគរ មួយថ្ងៃៗនៅក្នុងព្រះរាជវាំងផឹកស្រវឹង និងប្រព្រឹត្តអំពើស្មោកគ្រោកជាច្រើន។ នៅក្នុងការជប់លៀងមានស្តេចជាច្រើន ព្រមទាំងឥស្សរជនជាន់ខ្ពស់ក្នុងជួររដ្ឋាភិបាលប្រមាណរាប់ពាន់នាក់បានចូលរួម។ នៅក្នុងពេលនោះ កើតមានបញ្ហាស្មុគស្មាញ នៅក្នុងព្រះរាជវាំងនៃព្រះបាទស៊ូរុស។ ព្រះនាងវ៉ាសធីមិនបានស្តាប់បង្គាប់បញ្ជាស្វាមីរបស់ខ្លួន។ តើរឿងអគ្គមហេសីរបស់ស្តេចមួយអង្គ ដែលមិនស្គាល់ព្រះទាល់តែសោះ មិនស្តាប់បង្គាប់ដល់ប្តីរបស់ខ្លួន ជារឿងដែលព្រះជាម្ចាស់អាចប្រើបានដែរឬទេ? រឿងនេះ ព្រះអង្គអាចប្រើប្រាស់បាន ទោះបីស្ថានការណ៍នោះ មើលទៅហាក់ដូចជាអាក្រក់យ៉ាងណាក៏ដោយ។ ព្រះអង្គបានប្រើស្ថានភាពនោះ ដោយលើកសាសន៍របស់ទ្រង់មួយរូប ដាក់អោយធ្វើជាមនុស្សទីពីរសោយរាជ្យជាមួយនឹងស្តេចស៊ូរុស។ នាងអេសធើរ ជាមធ្យោបាយដើម្បីដោះស្រាយបញ្ហារបស់សាសន៍យូដា។ ព្រះជាម្ចាស់ធ្វើការជាមួយនឹងមនុស្សលោក ដើម្បីផ្តល់សេចក្តីឧបត្ថម្ភគាំទ្រ អោយមនុស្សលោកអាចរស់នៅក្នុងប្រវត្តិសាស្ត្រកន្លងទៅ។

ព្រះជាម្ចាស់សម្តែងពីការឧបត្ថម្ភគាំទ្រ ដល់មនុស្សលោកនៅក្នុងដំណើរដែលព្រះជាម្ចាស់ បញ្ជូនព្រះរាជបុត្រារបស់ទ្រង់ អោយមកប្រសូតនៅលើផែនដីនេះ។

ព្រះបន្ទូលបានសន្យាថា ព្រះអម្ចាស់យេស៊ូវត្រូវប្រសូតនៅភូមិបេថ្លេហិម។ នាងម៉ារា និងយ៉ូសែបមិនបានរស់នៅក្នុងភូមិបេថ្លេហិមទេ នៅក្នុងពេលដែលនាងម៉ារាជិតប្រសូតបុត្រ។ នៅពេលនោះស្តេចសេសារអូគូស បានចេញព្រះរាជក្រឹត្យដើម្បីបង្គាប់អោយមនុស្សគ្រប់រូប ត្រូវទៅចុះឈ្មោះបង់ពន្ធដារនៅក្នុងស្រុកកំណើតរបស់ខ្លួន។ ដោយសារព្រះរាជក្រឹត្យរបស់ព្រះបាទសេសារ នាងម៉ារា និងយ៉ូសែបត្រូវត្រឡប់ទៅភូមិស្រុករបស់ខ្លួនវិញ គឺភូមិបេថ្លេហិម។ នៅពេលនោះព្រះយេស៊ូវត្រូវប្រសូតនៅភូមិបេថ្លេហិមដូចព្រះជាម្ចាស់ទ្រង់កំណត់ទុកមែន។ នៅចំពោះស្តេចសេសារ ស្តេចអង្គនេះមិនខ្វល់ពីបុត្រាយេស៊ូវប្រសូតនៅទីនោះទេ ស្តេចអង្គនេះត្រូវការតែលុយប៉ុណ្ណោះ។ ប៉ុន្តែព្រះជាម្ចាស់បានប្រើវិធីដែលស្តេចសេសារប្រើ ដើម្បីសម្រេចទិសដៅរបស់ទ្រង់។ ព្រះជាម្ចាស់គ្រប់គ្រងរាជបល្ល័ង្ករបស់ស្តេចសេសារ។ ព្រះជាម្ចាស់គ្រប់គ្រងរាជបល្ល័ង្ករបស់ស្តេចស៊ីរុស។ ព្រះជាម្ចាស់ឈរនៅពីក្រោយឆាកនៅគ្រប់ស្ថានការណ៍ដែល កើតឡើងនៅក្នុងប្រវត្តិសាស្រ្តរបស់មនុស្សលោក ចាប់តាំងពីមនុស្សលោកមាននៅលើផែនដីនេះ។

# ជំពូក ៤

***ឆាទចនា*** *ក្នុងកាលៈទេសៈបែបនេះ*

ព្រះរាជក្រឹត្យដែលសម្តែងថា នៅថ្ងៃមួយពលរដ្ឋនៅក្នុងចក្រភពពើស៊ីទាំងមូល អាចសម្លាប់សាសន៍យូដាដោយត្រឹមត្រូវតាមច្បាប់។ ព្រះរាជក្រឹត្យនេះមានលក្ខណៈ អាក្រក់យ៉ាងខ្លាំងមហិមា។ កំពុងតែព្រះរាជក្រឹត្យបានត្រូវបញ្ជូនទៅដល់កន្លែងដែលត្រូវអោយពលរដ្ឋដឹង លោកហាម៉ាន មានសេចក្តីរីករាយយ៉ាងខ្លាំងឥតឧបមា។ ប៉ុន្តែ ទន្ទឹម និងសេចក្តីសប្បាយរបស់លោកហាម៉ាន តើលោកម៉ាដេកាយមានប្រតិកម្មយ៉ាងណាដែរ? សូមលោកអ្នកមើលពីប្រតិកម្មដែលលោកមានទៅខាងក្រោមនេះ

**[១] ចំណែកម៉ាដេកាយ កាលបានដឹងពីការដែលកើតមកទាំងនោះ
ហើយ នោះគាត់ហែកអាវខ្លួន ហើយស្លៀកសំពត់ធ្មៃរោយផេះផង
រួចចេញទៅកណ្តាលទីក្រុងស្រែកឡើង ជាសំរែកយ៉ាងខ្លាំង
ហើយជូរចត់ [២] គាត់ក៏ទៅរហូតដល់មុខទ្វារព្រះរាជវាំង ដ្បិតគ្មាន
ច្បាប់នឹងចូលទៅក្នុងព្រះរាជវាំងទាំងស្លៀកសំពត់ធ្មៃបានឡើយ
(នាងអេសធើរ៤:១-២)។**

នៅពេលដែលលោកម៉ាដេកាយបានឮ ហើយបានឃើញព្រះរាជក្រឹត្យ ដែលចេញមកពីព្រះរាជា ដើម្បីសម្លាប់សាសន៍យូដាផ្ដាច់ពូជ លោកបានពាក់សំពត់ធ្មៃព្រមទាំងយកផេះលាយលើខ្លួនថែមទៀតផង។ សូមមើល លោកកំពុងតែសម្ដែងការព្រួយបារម្ភ និងការកើតទុក្ខចំពោះហេតុការណ៍ ដែលកើតមានឡើងចំពោះសាសន៍របស់លោក។ លោកជឿថា ព្រះរាជក្រឹត្យនោះមានសុពលភាពមួយរយភាគរយ។ លោកដឹងថា ព្រះរាជក្រឹត្យមិនអាចផ្លាស់ប្រែបាន។ នៅក្នុងគ្រានោះ ខ្ញុំសន្និដ្ឋានថា សាសន៍យូដាមានប្រមាណដប់ប្រាំលាននាក់ នៅក្នុងចក្រភពពើស៊ីទាំងមូល។ ការសម្លាប់មនុស្សដប់ប្រាំលាននាក់ក្នុងរយៈពេលតែមួយថ្ងៃ មិនអាចធ្វើបានដោយគ្មានការបង្ហូរឈាម និងអំពើឧក្រិដ្ឋ ដែលត្រូវសម្រេចទៅលើជាតិសាសន៍នេះទេ។ ការសម្លាប់រង្គាលដល់ជាតិសាសន៍យូដា មិនគួរធ្វើឡើយ ហើយមិនចាំបាច់នឹងធ្វើដែរ។ ប៉ុន្តែ ដោយសារមនុស្សម្នាក់មិនព្រមលុតជង្គង់ក្រាបថ្វាយបង្គំហាម៉ាន ជាតិសាសន៍យូដាទាំងមូលត្រូវគេប៉ងសម្លាប់ផ្ដាច់ពូជ។ ហេតុការណ៍ដែលកើតឡើងនេះ កើតឡើងដោយសារមានឥស្សរជនមួយរូបនៅក្នុងជួររាជការចក្រភពពើស៊ី មិនព្រមក្រាបថ្វាយបង្គំដល់ហាម៉ានជានាយករដ្ឋមន្ត្រី។ ដោយសារមូលហេតុនោះ ហាម៉ានមានចិត្តខឹងសម្បារយ៉ាងឃោរឃៅ រហូតដល់ធ្វើគម្រោងការប្រើច្បាប់របស់នគរជាយាន ដើម្បីសម្លាប់សាសន៍យូដាផ្ដាច់ពូជមិនអោយសល់ម្នាក់ឡើយ។ ការនេះមិនមែនជាកិច្ចការរបស់ហាម៉ានតែម្នាក់ឯងទេ គឺសាតាំងស្ថិតនៅពីក្រោយផែនការរបស់លោកហាម៉ាន។ សាតាំងចង់សម្លាប់សាសន៍យូដា ដ្បិតសាសន៍យូដាជាមធ្យោបាយ ដែលព្រះអង្គសង្គ្រោះយាងមក

ប្រសូតនៅលើលោកនេះ។ ផែនការរបស់ហាម៉ាន ពិតជាផែនការរបស់សាតាំងឥតលើស ឥតខ្វះ ឥតក្រោម ឥតលើគឺចំចំណុចតែម្តង។

យើងស្លេះការសិក្សាគម្ពីរនាងអេសធើរត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"